# ចាក់ថ្នាំបង្ការរោគហើមថ្លើម តើអ្វីដែលអ្នកត្រូវតែដឹង

## តើអ្វីដែលអ្នកត្រូវតែដឹង

### ១ តើហេតុអ្វីបានជា ចាក់ថ្នាំបង្ការរោគ?

**រោគហើមថ្លើម ភេទបេ៊ី ជាជម្ងឺធ្ងន់មួយ។**

រោគហើមថ្លើម ភេទបេ៊ី វីរុស មានរយៈខ្លី (ឈឺធ្ងន់) អាចនាំឲ្យ :

- ធ្វើមិនឲ្យឃ្លាន
- រាគ និង ក្អួត
- មានភាពហត់
- យ៉ោនដឺស (រោគលឿងស្បែកឬភ្នែក)
- ឈឺចុកក្នុងសាច់ដុំ ក្នុងសន្ទាក់ និងក្នុងពោះ

វាអាចមានរយៈយូរដែរ (ឈឺរ៉ាំរ៉ៃ) ការឈឺនេះអាចនាំឲ្យ :

- ធ្វើឲ្យថ្លើមខូចខ្លី (រោគថ្លើម)
- រោគមហារីកថ្លើម
- ស្លាប់

មនុស្ស ប្រហែល ១.២៥ លានអ្នកឆ្លងរោគថ្លើមបេ៊ីរ៉ាំរៃនេះក្នុងសហរដ្ឋអាមេរិក។

ក្នុងមួយឆ្នាំៗគេអាចទាយថា :

- មានមនុស្ស ៨០,០០០អ្នក ភាគច្រើនគឺក្មេងទើបតែពេញវ័យ ឆ្លងរោគថ្លើមនេះ។
- មនុស្សច្រើនជាង១១,០០០អ្នកគេងក្នុងពេទ្យដោយរោគថ្លើមនេះ។
- ហើយមនុស្សពី ៤,០០០ទៅ៥,០០០ ស្លាប់ដោយរោគថ្លើមរ៉ាំរ៉ៃនេះ។

ថ្នាំបង្ការរោគថ្លើម ភេទប៊ីនេះ វាអាចការពារកុំឲ្យមានរោគថ្លើម ប៊ី។ វាគឺជាថ្នាំបង្ការរោគមហារីកពីមុនដូច្នេះ ហើយវាក៏អាចបង្ការរោគមហារីកថ្លើមដែរ។

### ២ តើរោគថ្លើមភេទប៊ី វីរុសនេះ ឆ្លងរបៀបណាដែរ?

រោគថ្លើមបេ៊ីនេះឆ្លងតាមការប៉ះឈាមឬទឹកក្នុងខ្លួនពីមនុស្សដែលមានរោគ នេះ។ យើងអាចឆ្លងតាមមនុស្សដែលមានរោគនេះ យ៉ាងច្រើនរបៀបដូចជា :

- គេងជាមួយមនុស្សដែលមានរោគនេះ ដោយគ្មានប្រើអ្វីមកការពារមុន
- ប្រើម្ជុលចាក់ថ្នាំជាមួយមនុស្សដែលចាក់ថ្នាំខុសច្បាប់
- មុតម្ជុលដែលជាប់នៅកន្លែងធ្វើការ
- ពេលសំរាលកូនចេញពីម្តាយដែលមានរោគនេះ

ប្រហែលមាន ១ ក្នុងមនុស្ស ៣ អ្នកមិនដឹងថាតើ ឆ្លងរោគថ្លើមប៊ីនេះដោយរបៀបណាទេ។

Hepatitis B VIS - Cambodian 7/11/01
Translation provided by Minnesota Department of Health

### ៣ នរណាដែលគួរចាក់ថ្នាំការពាររោគថ្លើមប៊ីនេះ ហើយពេលណា?

1) គ្រប់ក្មេងដែលមានអាយុក្រោម ១៨ ឆ្នាំ
2) ក្មេង ដែលមានអាយុលើសពី ១៨ ឆ្នាំ ហើយដឹងថាអាចមានរោគនេះ។

ក្មេងទើបតែពេញវ័យហើយដឹងថាអាចមានរោគនេះ :
- មនុស្សដែលដេររួមដំណេក ច្រើនជាងមនុស្សម្នាក់ ក្នុង ៦ ខែ
- មនុស្សប្រុសដែលដេររួមដំណេកជាមួយមនុស្សប្រុស
- រួមដំណេកជាមនុស្សដែលកើតរោគនេះ
- មនុស្សដែលចាក់ថ្នាំខុសច្បាប់
- ធ្វើការនៅកន្លែងថែរក្សាសុខភាព ឬកន្លែងការពារសន្តិសុខដែលអាចមានមនុស្សទាំមករោគនេះ តាមឈាម ឬទឹកនៅក្នុងខ្លួន។
- ប៉ះមនុស្សដែលមានរោគថ្លើមប៊ីនេះ ពេលនៅក្នុងផ្ទះជាមួយ។
- ជាមួយអ្នកជម្ងឺដែលទៅលាងឈាមរាល់ដង

បើអ្នកមិនដឹងច្បាស់ទេ កុំហ៊ានប្រថុយ សូមសួរដុកទ័រ ឬអាំងហ្វីមីញេរ។

✓ **មនុស្សទាំងអស់ត្រូវចាក់ថ្នាំបង្ការរោគនេះ ឲ្យបានបីដងតាមតារាងកំណត់វា។**
*បើអ្នកដឹងថាអ្នកភ្លេចចាក់ថ្នាំ ឬដឹងថាវាហួសពេល ត្រូវទៅចាក់វាភ្លាម។*
*មិនចាំបាច់ទៅចាក់សារឡើងវិញទេ។*

| តារាងចាក់ថ្នាំបង្ការរោគថ្លើមប៊ី | | តើនរណា? | | |
|---|---|---|---|---|
| | | ចំពោះទារកដែលម្តាយមានរោគថ្លើមប៊ីនេះ | ចំពោះទារកដែលម្តាយគ្មានរោគថ្លើមប៊ីនេះ | ចំពោះក្មេងអាយុប្រចីនតិច ក្មេងជំទុង ឬ ក្មេងពេញវ័យ |
| តើពេលណា? | ថ្នាំចាក់លើកទីមួយ | នៅក្នុង ១២ ម៉ោងពេលកើតរួច | ពេលកើតរួចបានពីខែ | ពេលណាក៏បាន |
| | ថ្នាំចាក់ការពារទីពីរ | ពី អាយុ១ខែទៅ ២ខែ | ពី អាយុ១ខែទៅ៤ខែ (ចាំយ៉ាងតិចណាស់ឲ្យបាន ១ខែ) | ពី ១ខែទៅ២ខែ បន្ទាប់ពីទីមួយ |
| | ថ្នាំចាក់ការពារទីបី | ពីអាយុ ៦ខែ | ពីអាយុ ៦ខែ ទៅ១៨ខែ | ពី ៤ខែទៅ៦ខែ បន្ទាប់ពីទីមួយ |

- ថ្នាំចាក់ការពារទីពីរ ចាំយ៉ាងតិចណាស់ឲ្យបាន ១ខែ បន្ទាប់ពីទីមួយរួច។
- ថ្នាំចាក់ការពារទីបី ចាំយ៉ាងតិចណាស់ឲ្យបាន ពីរខែ បន្ទាប់ពីទីពីររួច ហើយចាំយ៉ាងតិចឲ្យបាន៤ខែបន្ទាប់ថ្នាំចាក់ទីមួយរួច។
- ថ្នាំទីបីមិនអាចចាក់បង្ការឲ្យទារកក្រោមអាយុ ៦ខែទេ ពីព្រោះវាមានភាពរស់ថយពេលទៅមុខយូរទៀត។

ក្មេងជំទុង ដែលមានអាយុ ១១ ទៅ ១៥ឆ្នាំ អាចចាក់បង្ការរោគតែពីរដងប៉ុណ្ណោះទេ។ វាបំបែកចេញពីគ្នាពី ៤-៦ខែ។ សួរអ្នកថែរក្សាសុខភាពអ្នកបើចង់ដឹងសព្វគ្រប់។

ថ្នាំបង្ការរោគភេទប៊ីនេះអាចចាក់ក្នុងពេលជាមួយថ្នាំបង្ការរោគផ្សេងទៀត។

## ៤ ចំពោះមនុស្សខ្លះមិនគួរចាក់ថ្នាំបង្ការរោគថ្លើមប៊ីទេ គួរតែរងចាំ

ចំពោះមនុស្សខ្លះមិនគួរ ចាក់ថ្នាំបង្ការរោគថ្លើមប៊ី ទេ បើប្រសិនបើជីវិតគេមានបញ្ហាដោយសារការធ្វើទុក្ខ ពីមេដុត (មេម្សៅដែលយកមកធ្វើនំប៉័ង) ឬការធ្វើទុក្ខដោយសារ **ការចាក់បង្ការរោគថ្លើមភេទប៊ី ពីមុនមក។**



ចំពោះមនុស្សដែល ឈឺបន្តិចបន្តួច ឬ ខ្លាំងនៅពេលដល់ថ្ងៃចាក់ថ្នាំបង្ការរោគ តាមធម្មតាគេត្រូវតែរងចាំរហូតទាល់ ជាសិន។

សូមសួរអ្នកមើលថែរក្សារ ឬអាំងហ្វីមេញេ បើចង់ដឹងដំណឹងផ្សេងៗទៀត។

## ៥ បើចាក់ថ្នាំបង្ការរោគថ្លើមប៊ី តើអាចមាន គ្រោះថ្នាក់អ្វីកើតឡើង?

ទោះបីយ៉ាងណាក៏ដោយ ថ្នាំចាក់ការពារ ក៏វាអាចមានបញ្ហាខ្លាំងខ្លះដែរ ដូចជាការប្រែប្រួលក្នុងខ្លួនយើងដែលមិនអាចទទួលបាន។ មនុស្សភាគតិច ណាស់ ដែលអាចមានឈឺ ឬ មានគ្រោះថ្នាក់ដល់ស្លាប់ ក្នុងការចាក់បង្ការ រោគថ្លើមនេះ។

ចាក់បង្ការរោគថ្លើមប៊ីនេះមុន ក៏វាគ្រាប់បើជាងទុកឲ្យវាកើតរោគថ្លើមប៊ី ដែរ។

មនុស្សជាច្រើនដែលបានចាក់បង្ការវា មិនដែលមានបញ្ហារអំពីរោគថ្លើមប៊ីនេះទេ។

**អាចមានបញ្ហាតិចដែរ**

- ឈឺនៅកន្លែងចាក់ថ្នាំ ពីមួយថ្ងៃទៅពីរថ្ងៃដែរ (គឺមានក្មេង ១ឈឺក្នុងក្មេង១១អ្នក បើក្មេងទើបតែពេញវ័យមាន ១ឈឺក្នុង៤ អ្នក)
- អាចមានរោគគ្រុណក្តៅពីតិចទៅខ្លាំងល្មមដែរ (មានក្មេង ១ឈឺក្នុងក្មេង១៤អ្នក ចំពោះក្មេងទើបនឹងពេញវ័យមាន ១ក្នុង១០០អ្នក)

**បញ្ហាធំធ្ងន់**

- ការទាស់ ឬការប្រែប្រួលខ្លាំង (គឺវាកម្រមាន)

## ៦ តើអ្វីទៅ ដែលអាចធ្វើដំណើរប្រែប្រួលខ្លាំង ឬ តិចនៅក្នុងខ្លួន?

**តើខ្ញុំត្រូវកត់សំគាល់អ្វី?**

លក្ខណខ្លះ ដែលមិនធម្មតាហើយមាន ការប្រែប្រួលខ្លាំង ដូចជាគ្រុនក្តៅខ្លាំង ឬ ចរិកមិនធម្មតា។ វាកម្រមានការប្រែប្រួលខ្លាំង ពេលចាក់ថ្នាំរួច។ បើសិនជាមាន វានឹងកើតឡើងក្នុងរយះ ពេល ពីពីរនាទី ទៅពីរបីម៉ោង បន្ទាប់ពីរចាក់ថ្នាំរួច។ វាឲ្យសញ្ញាដូចជា ពិបាកដកដង្ហើម ស្អក ដកដង្ហើមសូរគ្រេតគ្រេត ស្ទាំង ខ្សោយ បេះដូងដើរលឿន វិលមុខ។ បើប្រសិនជាមានគ្រុនក្តៅ ឬ រោគប្រកាច់ វាត្រូវតែកើតឡើង នៅក្នុងរយះមួយអាទិត្យបន្ទាប់ ពីចាក់ថ្នាំរួច។

**តើខ្ញុំនឹងគួរធ្វើដូចម្តេច?**

- ទូរស័ព្ទទៅដុកទ័រ ឬ ឲ្យនរណាជូនទៅដុកទ័រភ្លាមៗ។
- ប្រាប់ដុកទ័រ អ្វីដែលប្រែប្រួល ថ្ងៃណា ពេលណាដែលកើតបន្ទាប់ ពីចាក់ថ្នាំរួច។
- សុំស្នើរដុកទ័រ អាំងហ្វីមីញេរ ឬកន្លែងថែរក្សារខាងសុខភាព កត់ទុកក្នុងបញ្ជីរាយការណ៍នូវពេលចាក់ថ្នាំការពារមានការប្រែប្រួលក្នុងខ្លួនហៅថា (វីអេអ៊ុអរអេស)ឬ ទុរស័ព្ទលេខ **១-៨០០-៨២២-៧៩៦៧។**

## ៧ ការចាក់ថ្នាំការពាររបួស គឺសំពប់ជាតិ ហើយគេមានវិធីការសងវិញ

អ្នកកម្រមានព្រឹត្តិការណ៏ ឬ បើកូនអ្នកមានការប្រែប្រួលខ្លាំង ពេលចាក់ ថ្នាំការពាររួច វិធីខាងសហព័ន្ធនឹងជួយចេញប្រាក់ទៅអ្នកដែលមានគ្រោះថ្នាក់។

បើចង់ដឹងដំណឹងសព្វគ្រប់ទៀត ពីរឿងការសង ក្រោយពីការចាក់ថ្នាំការពារ របួសសំពប់ជាតិរួច សូមទូរស័ព្ទ **១-៨០០-៣៣៨-២៣៨២** ឬ ឆែក វិបសៃ **http://www.hrsa.gov/osp/vicp/**

## ៨ តេខ្ញុំអាចរៀនថែមទៀតតាមរបៀបណា?

- សួរកន្លែងអ្នកទៅមើលថែរក្សារសុខភាព។ គេអាចឲ្យបញ្ជីមើលពីលទ្ធផលពីចាក់ថ្នាំការពារ ហើយដំណឹងផ្សេងៗ ហើយនិងកន្លែងរបស់វា។
- ទូរស័ព្ទទៅកន្លែងថែរក្សារសុខភាពសំរាប់ធ្វើឲ្យសាំងរោគ របស់រដ្ឋ ដែលនៅជិតផ្ទះអ្នក។
- ទូរស័ព្ទទៅកន្លែងការពារ និងបញ្ឈប់កុំឲ្យមានរោគ ហៅថា (ស៊ីឌីស៊ី)
  - **Call 1-800-232-4636 (1-800-CDC-INFO)**
  - ឆែកមើល វិបសៃ ខាងវិធីធ្វើឲ្យសាំងនឹងរោគ **http://www.cdc.gov/nip** ឬឆែកមើលផ្នែកខាង ស៊ីឌីស៊ីរោគថ្លើមដែលមានវីរុសនៅ វិបសៃឬទំព័រ **http://www.cdc.gov/hepatitis**

**U.S. DEPARTMENT OF HEALTH & HUMAN SERVICES**
Centers for Disease Control and Prevention
National Immunization Program

Vaccine Information Statement
Hepatitis B (7/11/01) - Cambodian 42 U.S.C. § 300aa-26

Translation provided by Minnesota Department of Health